01737740

5/2

# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០៣/០៨-១០-២០២១-អវតក/អជតក(០៥) |
| ដាក់ទៅ | : | អង្គជំនុំជម្រះតុលាការកំពូល |
| ថ្ងៃដាក់ | : | ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៤ |
| ភាគីអ្នកដាក់ | : | ការិយាល័យរដ្ឋបាល |
| ភាសាដើម | : | អង់គ្លេស, ខ្មែរ |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ ក.ស.ច.ស. ឬ អង្គជំនុំជម្រះ:

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 27 / 09 / 2024
ម៉ោង (Time/Heure): 08:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

## សេចក្ដីសង្ខេបរបស់ការិយាល័យរដ្ឋបាលលើការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ ដែលបានស្នើឡើងក្នុងសំណុំរឿង ០០៣

<u>អ្នកដាក់ឯកសារ:</u>
ការិយាល័យរដ្ឋបាល

<u>អ្នកទទួលឯកសារ:</u>
សហព្រះរាជអាជ្ញា
សហមេធាវីការពារក្ដី មាស មុត
សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី
ផ្នែកគាំពារការការពារក្ដី
អង្គភាពគាំពារសាក្សី និងអ្នកជំនាញ
ផ្នែកគ្រប់គ្រងតុលាការ

1. អនុលោមតាមការអញ្ជើញរបស់អង្គជំនុំជម្រះតុលាការកំពូល ការិយាល័យរដ្ឋបាល ("រដ្ឋបាល") សូមផ្តល់ជូនការសង្កេតរបស់ខ្លួនលើការអនុម័តប្រើគោលការណ៍ណែនាំស្តីពីការធ្វើចំណាត់ថ្នាក់ឯកសារឡើងក្នុងសំណុំរឿង ០០២ ចំពោះឯកសារក្នុងសំណុំរឿង ០០៣[1]។

2. រដ្ឋបាលគាំទ្រការដកចំណាត់ថ្នាក់កំណត់ត្រាឱ្យបានទូលំទូលាយបំផុត ស្របតាមក្របខ័ណ្ឌច្បាប់ អ.វ.ត.ក. (រួមទាំងសេចក្តីណែនាំអនុវត្តជាធរមាន) វិធានការការពារដែលចេញដោយតុលាការ និងសិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី[2]។

3. បណ្ណសាររបស់ អ.វ.ត.ក. បន្តទទួលបានចំណាប់អារម្មណ៍យ៉ាងខ្លាំងបន្ទាប់ពីការបញ្ចប់បញ្ជីឯកសារតុលាការ។ ជាមួយនឹងការចាប់ផ្តើមមុខងារសេសសល់ក្នុងឆ្នាំ២០២៣ រដ្ឋបាលតែងតែបានទទួលការសាកសួរព័ត៌មានជាបន្តបន្ទាប់ ទាក់ទងទៅនឹងការដកចំណាត់ថ្នាក់ឯកសារនាពេលខាងមុខ និងការចូលមើលបណ្ណសារជាសាធារណៈ រួមទាំងបន្ទាប់ពីការបិទបញ្ចប់ជាស្ថាពរនៃអង្គជំនុំជម្រះវិសាមញ្ញ[3]។ ការពិគ្រោះយោបល់ភាគីពាក់ព័ន្ធ បានគូសបញ្ជាក់ជាពិសេសអំពីសារៈសំខាន់ និងការបញ្ចេញឱ្យឃើញនៃបណ្ណសាររបស់ អ.វ.ត.ក. កំពុងឆ្ពោះទៅមុខ "*ដោយសារសារៈសំខាន់ និងភាពពាក់ព័ន្ធនៃព័ត៌មាន ដែលឯកសារទាំងនេះមានសម្រាប់ជនរងគ្រោះ គ្រួសារ សហគមន៍របស់ពួកគេ និងសម្រាប់សាធារណជនកម្ពុជា នាពេលបច្ចុប្បន្ន និងទៅអនាគត*"[4]។ ដូច្នេះ

---

[1] អនុស្សរណៈអន្តរការិយាល័យ "*ការដាក់ចំណាត់ថ្នាក់ឯកសារឡើងវិញក្នុងសំណុំរឿង ០០៣*" ឯកសារលេខ 5 ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៤។

[2] សូមមើល *សេចក្តីសង្កេតរបស់ការិយាល័យរដ្ឋបាល ស្តីពីសំណើសុំធ្វើចំណាត់ប្រភេទឡើងវិញទៅលើឯកសារក្នុងសំណុំរឿង ០០២* ឯកសារ F71/1/1/2 ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២។

[3] សូមមើល *កិច្ចព្រមព្រៀងបន្ថែមទៅនឹងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ស្តីពីការរៀបចំក្នុងពេលអន្តរកាល និងការបញ្ចប់ការងាររបស់ អ.វ.ត.ក.* ("*កិច្ចព្រមព្រៀងបន្ថែម*")។ មាត្រា ២(១) ផ្តល់ឱ្យ អ.វ.ត.ក. នូវមុខងារសេសសល់សម្រាប់ "រយៈពេលបីឆ្នាំដំបូង" ដែលបញ្ចប់ក្នុងខែធ្នូ ឆ្នាំ២០២៥។ វឌ្ឍនភាពនៃមុខងារទាំងអស់នេះ និងរយៈពេលនឹងត្រូវពិនិត្យដោយភាគីអត្តលេខីអនុលោមតាមមាត្រា ២(២)។

[4] Cohen, D., Mattes, D., Yogendran, S., *របាយការណ៍សិក្ខាសាលា ពាក់ព័ន្ធនឹងសកម្មភាពជនរងគ្រោះនៅក្នុងអំឡុងពេលអនុវត្តអាណត្តិសេសសល់របស់ អ.វ.ត.ក.* ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២២ ទំព័រ ៣៧ មាននៅ <https://eccc.gov.kh/en/publication/report-workshop-victim-related-activities-during-residual-mandate>។ សូមមើលជាពិសេសសំណើពីក្រុម ៣ ផ្តោតលើបណ្ណសារ និងឯកសារជនរងគ្រោះ នៅទំព័រ ១៣៥-១៣៧ ("*ក្រុមនេះយល់ស្របថា គោលដៅគឺចង់ឱ្យមានការចូលប្រើប្រាស់បានទូលំទូលាយរហូតដល់ចំនួនឯកសារតុលាការជាអតិបរមា ដរាបណាវាស្របជាមួយនឹងភាពឯកជន និងផលប្រយោជន៍ផ្សេងទៀត ដូចជាសិទ្ធិអ្នកប្រើប្រាស់។ ដូច្នេះ នេះមានន័យថា ការចាត់ថ្នាក់*

ការចូលមើលជាទូទៅនៃព័ត៌មានអំពីកិច្ចដំណើរការនីតិវិធី អ.វ.ត.ក. *ទាំងអស់* មានភាពចាំបាច់ខ្លាំងណាស់។ ការណ៍នេះមានសារៈសំខាន់ជាពិសេសក្នុងបរិបទនៃសំណុំរឿង ០០៣,[5] ០០៤, ០០៤/០១ និង ០០៤/០២ ដែលបច្ចុប្បន្ននេះមានព័ត៌មានតិចតួចអំពីសំណុំរឿងទាំងនេះនៅក្នុងចំណោមសាធារណជន និងដែលជាលទ្ធផលនាំឱ្យមានការទាញស្មាន និងការផ្ដល់ព័ត៌មាន មិនត្រឹម ត្រូវ។

4. រដ្ឋបាលយល់ឃើញថា ការពិនិត្យឡើងវិញបន្ថែមទៀត និងការដកចំណាត់ថ្នាក់ឯកសារ *ក្នុងសំណុំរឿងទាំងអស់* គឺជាតម្រូវការចាំងបាច់ ហើយនឹងជួយសម្រួលដល់ការចូលមើលព័ត៌មានអំពីអង្គជំនុំជម្រះវិសាមញ្ញ និងការងាររបស់ខ្លួន បង្កើនការយល់ដឹងអំពីបទពិសោធន៍កម្ពុជា ទទួលស្គាល់ទុក្ខលំបាករបស់ជនរងគ្រោះនៃរបបខ្មែរក្រហម ផ្ដល់ការគោរពនិងកោតសរសើរដល់ជនរងគ្រោះ អ្នកដែលរស់រានមានជីវិត និងចូលរួមចំណែកដល់ការទប់ស្កាត់អំពើឃោរឃៅ និងការមិនកើតមានជាថ្មី តាមរយៈការចងក្រងឯកសារ ការអប់រំ ការចងចាំ និងការរំលឹក។ ព័ត៌មានដែលមានក៏អាចប្រើបន្ថែមទៀតជាទម្រង់មួយនៃសំណង តាមរយៈការពេញចិត្តរបស់ជនរងគ្រោះដោយការទទួលស្គាល់ព្យសនកម្ម និងអំពើឃោរឃៅ ការដាក់បង្ហាញជាសាធារណៈនូវការកើតមានការរំលោភបំពាន និងការស្ដារឡើងវិញនូវសិទ្ធិ និងសេចក្ដីថ្លៃថ្នូររបស់ជនរងគ្រោះ[6]។

5. យោងតាមកំណត់ត្រាអង្គភាពបណ្ណសារ គិតត្រឹមការសរសេរសេចក្ដីសង្ខេបនេះ ស្ថានភាពចំណាត់ថ្នាក់ឯកសារក្នុងសំណុំរឿងមានដូចខាងក្រោម៖

| សំណុំរឿង | សាធារណៈ | សម្ងាត់ | សម្ងាត់បំផុត | សរុប | % នៃសំណុំរឿងដែលសាធារណៈ |
|---|---|---|---|---|---|
| ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ | - | ៣.៨៤០ | - | ៣.៨៤០ | 0.0% |
| ០០១ | ៨.០៥៨ | ១០.៥៥២ | ២៤១ | ១៨.៨៥១ | ៤២.៧% |

*ឡើងវិញមានសារៈសំខាន់ណាស់ក្នុងការសម្រេចបាននូវគោលដៅនេះ ហើយគួរតែត្រូវបានចាត់ទុកថាជាការងារអាទិភាពខ្ពស់សម្រាប់ចៅក្រម បន្ទាប់ពីចេញសាលដីកាលើបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០២។")*។

[5] រួមបញ្ចូលទាំងការស៊ើបអង្កេតក្នុងរឿងក្ដី ស៊ូ ម៉េត។

[6] សូមមើល ឧទាហរណ៍ *គោលការណ៍និងសេចក្ដីណែនាំមូលដ្ឋានស្ដីពីសិទ្ធិទទួលបានដំណោះស្រាយ និងសំណង សម្រាប់ជនរងគ្រោះនៃការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ (Basic Principles and Guidelines on the Right to a Remedy and Reparation for Victims of Gross Violations of International Human Rights Law and Serious Violations of International Humanitarian Law)*, A/RES/60/147 ជំពូក IX។

| | | | | | |
|---|---|---|---|---|---|
| 00២[7] | ៥៥.៧៤៧ | ៩៨.៥៣៤ | ៤.៨៣០ | ១៥៩.១១១ | ៣៥.០% |
| 00៣ | ២.៣១៦ | ២១.៨២៨ | ៩៤ | ២៤.២៣៨ | ៩.៦% |
| 00៤ | ២.៦១៣ | ៣៥.១៥០ | ៤៥ | ៣៧.៨០៨ | ៦.៩% |
| 00៤/0១[8] | ១.២៨៣ | ២៧.៧៩៧ | ២៤ | ២៩.១០៤ | ៤.៤% |
| 00៤/0២[9] | ១.៩៨៦ | ៣៣.៤២២ | ៥៣ | ៣៥.៤៦១ | ៥.៦% |
| **រឿងក្តីរបៀប** | ៦៣៤ | ៧៨៧ | ២៣៤ | ១.៦៥៥ | **៣៨.៣%** |
| **សរុបរួម** | **៧២.៦៣៧** | **២៣១.៩១០** | **៥.៤២១** | **៣១០.០៦៨** | **២៣.៤%** |

*ចំនួនឯកសារក្នុងសំណុំរឿង តាមចំណាត់ថ្នាក់ (ចំនួនទំព័រមិនមានបង្ហាញទេ)*

6. រដ្ឋបាលមិនមែនជាភាគីមួយនៃកិច្ចដំណើរការនីតិវិធីទេ ហើយដូច្នេះរដ្ឋបាលកំណត់ព្រំដែនរបស់ខ្លួនត្រឹមតែការផ្តល់យោបល់ទូទៅថាឯកសារមានតម្លៃជាប្រវត្តិសាស្ត្រ ឬជាកេរដំណែលរបស់កម្ពុជា ឬ អ.វ.ត.ក. ត្រូវដកចំណាត់ថ្នាក់សម្ងាត់ចេញ អនុលោមតាមនីតិវិធីជាធរមាន។ ក្នុងន័យនេះ រដ្ឋបាលគាំទ្រការអនុម័តប្រើគោលការណ៍ណែនាំក្នុងសំណុំរឿង 00២ ចំពោះសំណុំរឿង 00៣ ដោយមានការសង្កេតថា*ការកោសលុប*ក្នុងឯកសារទាំងនោះ - ជាជាងការដាក់ឯកសារទាំងស្រុងជាឯកសារសម្ងាត់[10] - អាចធ្វើឱ្យមានតុល្យភាពសមស្របរវាងការរក្សាផលប្រយោជន៍ស្របច្បាប់ ដូចជាភាពឯកជនដែលមានក្នុងឯកសារ និងពង្រីកតម្លាភាពជាអតិបរមា ហើយម្យ៉ាងវិញទៀត ក៏ដូចជាការចូលពិនិត្យកំណត់ត្រា អ.វ.ត.ក. ជាសាធារណៈផងដែរ[11]។ វិធីសាស្ត្រនេះស្របទៅនឹងការព្រមព្រៀងរបស់ភាគីអគ្គលេខាធិការទៅនឹងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាល

---

[7] បន្ទាប់ពីការអនុវត្តការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញចុងក្រោយក្នុងសំណុំរឿង 00២។ សូមមើល *អនុស្សរណៈអង្គភាពបណ្ណសារ* ឯកសារ F71/1/1/10 ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២៤។

[8] សំណុំរឿង 00៤/0១ និង 00៤/0២ រួមបញ្ចូលការដាក់ឯកសារមុនដីកាបំបែកសំណុំរឿងពីសំណុំរឿង 00៤។

[9] មុនពេលអនុវត្តការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញថ្មីៗនេះក្នុងសំណុំរឿង 00៤/0២។ សូមមើល *ដីកាបង្គាប់ឱ្យធ្វើចំណាត់ថ្នាក់ឡើងវិញឯកសារដែលបានដាក់ក្នុងសំណុំរឿង 00៤/0២* ឯកសារ E004/2/7/2 ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៤។

[10] ដូចឃើញក្នុងតារាងខាងលើ ជាង ៧៦% នៃកំណត់ត្រារឿងក្តីទាំងអស់នៅតែចាត់ថ្នាក់ថាជាឯកសារសម្ងាត់ ឬសម្ងាត់បំផុត។

[11] សូមមើល *សេចក្តីសម្រេចស្តីពីសេចក្តីណែនាំសម្រាប់ការធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញក្នុងសំណុំរឿង 00២* ឯកសារ F71/1/1/8 ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣ កថាខណ្ឌ ២៦។ ដើម្បីបង្កើនការយល់ដឹងជាសាធារណៈអំពីរបៀបដែលអង្គជំនុំជម្រះបានថ្លឹងថ្លែងការពិចារណាទាំងនេះ សេចក្តីសម្រេចនាពេលអនាគតលើគោលការណ៍ណែនាំ ឬដីកាសម្រេចលើការធ្វើចំណាត់ថ្នាក់ឡើងវិញ នឹងទទួលបានអត្ថប្រយោជន៍ពីឧបសម្ព័ន្ធដែលបានដាក់ជាសាធារណៈ អមដោយការកោសលុប ប្រសិនបើចាំបាច់ ការកំណត់ថាតើឯកសារមួយណា ឬប្រភេទណា ដែលស្ថិតនៅក្រោមការរក្សាការសម្ងាត់ទាំងស្រុង ឬដោយមានការកោសលុប។

កម្ពុជា និងកិច្ចព្រមព្រៀងបន្ថែមរបស់ខ្លួនដែលថា *"ជាការសំខាន់ដែលធានាថាបណ្ណសាររបស់អង្គជំនុំជម្រះវិសាមញ្ញ... សាធារណជនអាចចូលមើលបានយ៉ាងទូលំទូលាយ"*[12]។

7. រដ្ឋបាលកត់សម្គាល់លើគោលបំណងរបស់អង្គជំនុំជម្រះក្នុងការចេញ *"សេចក្តីសម្រេចទាក់ទងនឹងសំណើ* [របស់សហព្រះរាជអាជ្ញាអន្តរជាតិ] *សុំឱ្យ...បង្កើតសេចក្តីណែនាំស្តីពីការចូលប្រើប្រាស់ឯកសារ បន្ទាប់ពីដំណោះស្រាយ...សំណើនៅសេសសល់សុំធ្វើចំណាត់ថ្នាក់ឯកសារឡើងវិញ"*[13]។ រដ្ឋបាលគាំទ្រការបង្កើតគោលការណ៍ណែនាំបែបនោះ និងយល់ឃើញថាការធ្វើបែបនេះនឹងផ្តល់ឱ្យសាធារណជននូវភាពច្បាស់លាស់អំពីការចូលប្រើប្រាស់បណ្ណសាររបស់ អ.វ.ត.ក. ក្នុងរយៈពេលយូរ[14]។ យ៉ាងណាមិញ គោលការណ៍ណែនាំមួយមិនមែន និងមិនអាចជាការជំនួសឱ្យមុខងារសេសសល់ដែលត្រូវបានកំណត់អាណត្តិនោះឡើយ - ដែលរួមមានការដកចំណាត់ថ្នាក់ឯកសារ និងសម្ភារៈ[15] - ខណៈពេលដែលអង្គជំនុំជម្រះវិសាមញ្ញនៅតែមានអត្ថិភាព មានហិរញ្ញប្បទាន និងប្រតិបត្តិការពេញលេញ ក្នុងក្របខ័ណ្ឌដែលមានស្រាប់របស់ខ្លួនក្រោមច្បាប់ជាតិ និងអន្តរជាតិ។ ដើម្បីឱ្យការបិទបញ្ចប់អង្គជំនុំជម្រះវិសាមញ្ញធ្វើទៅបានតាមលំដាប់លំដោយ មុខងារសេសសល់ទាំងអស់ត្រូវតែទាន់ពេលវេលា និងអនុវត្តពេញលេញ។

8. រដ្ឋបាលត្រៀមខ្លួនជាស្រេចដើម្បីជួយជ្រោមជ្រែងដល់ដំណើរការដកចំណាត់ថ្នាក់ឯកសារ តាមការណែនាំរបស់អង្គជំនុំជម្រះ។

ដាក់ជូនដោយក្តីគោរព

| | | | |
|---|---|---|---|
| ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២៤ | **ឯកឧត្តម ក្រាញ់ តូនី**<br>ប្រធានរដ្ឋបាលស្តីទី | ភ្នំពេញ | |
| | **លោក Knut Rosandhaug**<br>អនុប្រធានរដ្ឋបាល | | |

---

[12] *កិច្ចព្រមព្រៀងបន្ថែម* មាត្រា ៣(១) [គូសបញ្ជាក់បន្ថែម]។

[13] *ដីកាបង្គាប់ឱ្យធ្វើចំណាត់ថ្នាក់ឡើងវិញឯកសារដែលបានដាក់ក្នុងសំណុំរឿង ០០៤/០២* ឯកសារ E004/2/7/2 ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៤ កថាខណ្ឌ ១២។

[14] រដ្ឋបាលមានបំណងផ្តល់ឱ្យអង្គជំនុំជម្រះនូវសេចក្តីសង្កេតរបស់ខ្លួនលើគោលការណ៍បែបនេះនៅពេលសមស្រប។

[15] សូមមើល *កិច្ចព្រមព្រៀងបន្ថែម* មាត្រា ២(១)។